**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~x~~~~~

**ក្រសួងពាណិជ្ជកម្ម**

**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**

~~~~x~~~~

# របាយការណ៍ការងារ

# ប្រចាំឆ្នាំ ២០០៩

# និង

# ទិសដៅការងារឆ្នាំ ២០១០

~~*~~

ដោយមានការខិតខំព្យាយាមក្នុងការងាររបស់ថ្នាក់ដឹកនាំនាយកដ្ឋាន មន្ត្រីរាជការទាំងអស់ ក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និង ដោយមានការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ទាំងផ្នែកស្មារតី និងសំភារៈ រួមទាំងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធិជាមួយនឹងស្ថាប័នជាតិ-អន្តរជាតិនានាផងនោះ ធ្វើអោយដំណើរការ កែលំអរ និងលើកកំពស់ការអនុវត្តវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាកាន់តែមានភាពរឹងមាំ និងល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ លទ្ធផលទាំងអស់នេះ ជាសមិទ្ធិផលមួយយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ ។ សកម្មភាពជាក់ស្តែងក្នុង ឆ្នាំ ២០០៩ នេះ នាយកដ្ឋានទទួលបាន លទ្ធផលមួយចំនួន ដូចខាងក្រោមៈ

## I- លទ្ធផលដែលទទួលបាន

### ក-ការងាររៀបចំច្បាប់ និង បទបញ្ញត្តិនានា :

#### ក១. ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម

ដោយមានការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន និង ដោយមានការជួយឧបត្ថម្ភគាំទ្រពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មនៅឆ្នាំ ២០០៩ កន្លងមកនេះ នាយកដ្ឋានសម្រេចបាននូវ ការរៀបចំច្បាប់ និង បទប្បញ្ញត្តិនានា ដូចខាងក្រោម :

ក១-១-បានបញ្ចប់ការបកប្រែសេចក្តីប្រកាស ស្តីពីភ្នាក់ងារកម្មសិទ្ធិបញ្ញា សៀវភៅណែនាំពាណិជ្ជសញ្ញា និង កិច្ចព្រម ព្រៀង ពាណិជ្ជកម្មសេរីរវាងអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ហើយកំពុងរង់ចាំការពិនិត្យ និង កែសម្រួលជាចុងក្រោយ ។

ក១-២-សេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានធ្វើរួចរាល់ហើយ ក្រោមការផ្តល់ជំនួយបច្ចេកទេសពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង “AFD” ។ បច្ចុប្បន្ន ច្បាប់នេះកំពុងដាក់អោយពិភាក្សា និង កែតម្រូវក្នុងក្របខ័ណ្ឌ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធបញ្ញា ហើយសង្ឃឹមថា ច្បាប់នេះនឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅត្រីមាសទី ១ ឆ្នាំ ២០១០ ។

ក១-៣-កំពុងព្រាងច្បាប់ ស្តីពីអាជ្ញាប័ណ្ណបញ្ជាសំរាប់សុខភាពសាធារណៈ ដើម្បីអនុវត្តអោយមានប្រសិទ្ធិភាពចំពោះវាក្យខណ្ឌទី ៦ នៃសេចក្តីប្រកាស កិច្ចព្រមព្រៀង TRIPS និង សុខភាពសាធារណៈ ត្រូវបានធ្វើរួចរាល់ តាំងពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧កន្លងមក ដោយជំនាញការកាណាដា ហើយបានបញ្ជូនទៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និង ក្រសួងសុខាភិបាល រួចរាល់ហើយដែរ ។

ដោយយល់ឃើញថា ច្បាប់នេះផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជាដែលកំពុងជួបប្រទះនូវកង្វះខាតថ្នាំពេទ្យចាំបាច់មួយចំនួន សម្រាប់បំរើសុខភាពសាធារណៈ ដែលកម្ពុជាខ្លួនឯងពុំមានលទ្ធភាពផលិត ធ្វើអោយថ្នាំពេទ្យមាន តម្លៃខ្ពស់ នាំអោយប្រជាជនពុំមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីទិញផលិតផលនេះបាន ។ ដូច្នេះវាមានសារៈសំខាន់ និង ចាំបាច់ណាស់ក្នុងការរៀបចំ និង ជំរុញការអនុម័តច្បាប់នេះអោយបានឆាប់ ដើម្បីអោយប្រទេសកម្ពុជាអាចចេញអាជ្ញា ប័ណ្ណបញ្ជា (Compulsory Licensing) ទៅប្រទេសនាំចេញណាមួយផលិត និងនាំចូលផលិតផលថ្នាំពេទ្យ ក្នុងតម្លៃថោក សមរម្យ សំរាប់បំរើទីផ្សារក្នុងស្រុក ។ ចំពោះសេចក្តីព្រាងច្បាប់ ស្តីពីអាជ្ញាប័ណ្ណបញ្ជាសំរាប់សុខភាពសាធារណៈនេះ នាយកដ្ឋានបាន រៀបចំលិខិតផ្ញើជូនក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល និង ក្រសួងសុខាភិបាល ដើម្បីជំរុការអនុវត្តច្បាប់ នេះរួចរាល់ហើយ ។

ក១-៤-បានរៀបចំបញ្ចូលគំរោងសកម្មភាពមួយចំនួន របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ទៅក្នុងផែនការយុទ្ធសាស្ត្រ ចតុកោណ ដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ក១-៥- បានសិក្សា និង ផ្តល់យោបល់ជូនក្រសួងសុខាភិបាល ទៅលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ ។

ក១-៦-បានចូលរួមប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីពង្រាងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលអាមេរិច និង រាជរដ្ឋា ភិបាលកម្ពុជា ស្តីពីការស្រាវជ្រាវជំងឺឆ្លង ។

ក១-៧-រៀបចំជាគំរោងលំអិតអនុវត្តកម្មសិទ្ធិបញ្ញា ដែលមាននៅក្នុង Pillar 1 ដើម្បីស្នើសុំធនាគារពិភពលោក ជួយ ឧបត្ថមក្នុងការអនុវត្តគម្រោងនេះ ។

ក១-៨-បានចូលរួមពិនិត្យ និង ពិភាក្សាស្តីពីសេចក្តីព្រាងអនុសារណៈយោគយល់រវាងក្រុមហ៊ុន Microsoft និង រដ្ឋាភិបាលកម្ពុជា ។

**ក២. ក្នុងក្របខ័ណ្ឌលេខាធិការដ្ឋាន នៃគណៈកម្មការគ្រប់គ្រងផ្នែកទាំង៣ នៃកម្មសិទ្ធបញ្ញា**

ក២-១- គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានរៀបចំកិច្ចប្រជុំលើទី ១ របស់ខ្លួនកាលពីថ្ងៃ ២០ ខែ មករា ឆ្នាំ ២០០៩ ដែលធ្វើការពិភាក្សាទៅលើ គំរោងអភិវឌ្ឍន៏ប្រព័ន្ធកម្មសិទ្ធិបញ្ញាកម្ពុជា ចំនួន ៣៩ សកម្មភាព ការបណ្តុះបណ្តាលធនធានមនុស្ស និង បានប្រគល់ភារកិច្ចអោយលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ពិនិត្យទៅលើ:

-សំណើ របស់ក្រុមហ៊ុន Microsoft ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា។

-សេចក្តីពន្យល់នៃវិធាន សំរាប់អនុវត្ត មាត្រា ១១ និង មាត្រា ១៣ នៃអនុសញ្ញាស្តីពី ការត្រួតពិនិត្យថ្នាំជក់ ក្របខ័ណ្ឌអង្គការ សុខភាពពិភពលោក (WHO Framework Convention on Tobacco Control) និងកិច្ចព្រមព្រៀង ទិដ្ឋភាពកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម (TRIPS Agreement) និងច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និង អំពើនៃ ការប្រកួត ប្រជែង មិនស្មោះត្រង់ ។

ក២-២- គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានរៀបចំកិច្ចប្រជុំលើទី ២ កាលពីថ្ងៃ ២០ ខែ សីហា ឆ្នាំ ២០០៩ ដែលពិភាក្សាស៊ីជម្រៅទៅលើ :

-កិច្ចសហប្រតិបត្តិការរបស់អជ្ញាធរមានសម្ថកិច្ច ទាក់ទងនឹងការដោះស្រាយវិវាទ និង ការអនុវត្តកម្មសិទ្ធិបញ្ញា

- សេចក្តីព្រាងច្បាប់អជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ

-កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Microsoft

-អង្គភាពគ្រប់គ្រងសិទ្ធិរួម (Collective Management Organization)

ក២-៣-គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានធ្វើសេចក្តីជូនដំណឹងដល់គ្រប់ស្ថានីយ៍ទូរទស្សន៍ស្តីពីការហាមចាក់ ផ្សាយបទចម្រៀងខារ៉ាអូខេ ខ្សែភាពយន្ត និង វីដេអូ ដែលគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

ក២-៤-លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានជួបប្រជុំកាលពីថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៩ ដោយបានពិនិត្យឃើញថា មានមាត្រាមួយចំនួន នៃសេចក្តីព្រាងច្បាប់ថ្នាំជក់ មិនទាន់ស៊ីសង្វាក់ទៅនឹង ច្បាប់ម៉ាកពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា។

ដោយសេចក្តីព្រាងច្បាប់នេះបានបញ្ជូនទៅ ទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ហើយក្រសួងពាណិជ្ជកម្មបានធ្វើលិខិតស្នើសុំទៅ ទីស្តីការគណៈរដ្ឋមន្ត្រី អោយអញ្ជើញក្រសួងពាក់ព័ន្ធចូលរួមពិភាក្សា លើសេចក្តីព្រាងច្បាប់ថ្នាំជក់ ក្នុងក្របខ័ណ្ឌកិច្ច ប្រជុំនៅ ទីស្តីការ គណៈរដ្ឋមន្ត្រី។

ក២-៥-របាយការណ៍ទាក់ទងកម្មសិទ្ធិបញ្ញា

ក២-៥-១-នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានធ្វើរបាយការណ៍ ស្តីពីការរំលោភបំពានកម្មសិទ្ធិបញ្ញា នៅក្នុងក្របខ័ណ្ឌនាយកដ្ឋាន ស្តីពីវិវាទម៉ាក និង នៅក្នុងក្របខណ្ឌអន្តរក្រសួង ស្តីពីការរឹបអូស កំទេច ស៊ីឌី ឌីវីឌី និង វីដេអូក្លែងក្លាយ និង ការបង្ក្រាបទំនិញ ដែលរំលោភកម្មសិទ្ធិបញ្ញា។

ក២-៥-២-លេខាធិការដ្ឋានគណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា បានរៀបចំចងក្រងជារបាយការណ៍រួម ប្រចាំឆមាស អំពីលទ្ធផល គុណសម្បត្តិ ការប្រឈម ដំណោះស្រាយ ទិសដៅ និងសំនូមពរ ទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញា របស់សមាជិក គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា។

## ខ-ការងារផ្សព្វផ្សាយ និង សហប្រតិបត្តិការអន្តរជាតិ

### ខ១-ការងារបណ្តុះបណ្តាល

នាយកដ្ឋានបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការផ្សព្វផ្សាយ និង ការពង្រឹងការការពារកម្មសិទ្ធិបញ្ញា នៅ តាមស្រទាប់សិស្ស និស្សិត ប្រជាជន ក៏ដូចជាអាជីវករទាំងអស់ ដើម្បីឱ្យពួកគេកាន់តែមានការយល់ដឹងស៊ីជម្រៅពីកម្មសិទ្ធិបញ្ញា និង ចូលរួមលើកស្ទួយការការពារកម្មសិទ្ធិបញ្ញា។ នៅឆ្នាំ ២០០៩ នេះ នាយកដ្ឋានបានបណ្តុះបណ្តាល អំពីមុខជំនាញកម្មសិទ្ធិបញ្ញា ក្នុងនិងក្រៅប្រទេស ជូនដល់មន្ត្រី នាយកដ្ឋាន និងក្រសួងពាក់ព័ន្ធ អាជីករ សាធារណជន ដោយមានការជួយឧបត្ថម្ភ ពីបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិនានា។ ការងារបណ្តុះបណ្តាលនេះ មានដូចខាងក្រោម :

### ខ១-១-រៀបចំសិក្ខាសាលាបំប៉នជំនាញកម្មសិទ្ធិបញ្ញា ក្នុងប្រទេសៈ

| | | |
|---|---|---|
| -បានធ្វើសិក្ខាសាលាក្នុងប្រទេស | ចំនួន | ០៨ លើក |
| ក្នុងនោះ ថ្នាក់តំបន់ | ចំនួន | ០៣ លើក |
| -សរុបសិក្ខាកាម | ចំនួន | ៤០៤ នាក់ |
| *ដែលក្នុងនោះ* | | |
| -ជនជាតិកម្ពុជា | ចំនួន | ៣៤៦ នាក់ |
| -ជនជាតិបរទេស | ចំនួន | ៥៨ នាក់ |

### ខ១-២-បញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាក្រៅប្រទេស

| | | |
|---|---|---|
| -សរុបចំនួនសិក្ខាសាលា ដែលបានចូលរួម | ចំនួន | ៤០ លើក |
| -សរុបសិក្ខាកាម ដែលបានចូលរួម | ចំនួន | ៩៤ នាក់ |
| *ដែលក្នុងនោះ* | | |
| -មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា | ចំនួន | ៤៥ នាក់ |
| -មន្ត្រីអង្គភាពពាក់ព័ន្ធ | ចំនួន | ៤៩ នាក់ |

### ខ១-៣-ការងារសហប្រតិបត្តិការអន្តរជាតិ

-នាយកដ្ឋានបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើការងារសហប្រតិបត្តិការអន្តរជាតិ ដោយពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយការិយាល័យកម្មសិទ្ធិបញ្ញាបរទេស និង អង្គការអន្តរជាតិនានា ស្វែងរកការឧបត្ថម្ភទាំងសម្ភារៈ បច្ចេកទេស និងការបណ្តុះ បណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីការិយាល័យកម្មសិទ្ធិបញ្ញា និង មន្ត្រីអនុវត្តកម្មសិទ្ធិបញ្ញា។

-បានធ្វើសំណើផ្លូវការនូវការបង្កើតកម្មវិធីថ្នាក់តំបន់ Regional Program on Geographical Indications Project សម្រាប់ ០៤ ប្រទេស ដោយបានស្នើសុំឱ្យបង្កើតការិយាល័យនេះ នៅក្នុងប្រទេសកម្ពុជា ទៅទីភ្នាក់ងារបារាំងដើម្បី ការអភិវឌ្ឍន៍ (AFD) ដើម្បីពិចារណា និងសម្រេចលើបេក្ខភាពរបស់ប្រទេសកម្ពុជា ។

-បានរៀបចំធ្វើសំណើសុំជំនួយបច្ចេកទេសពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដើម្បីដាក់ក្នុង គម្រោង អភិវឌ្ឍន៏វិស័យកម្មសិទ្ធិបញ្ញា ក្នុងរយៈពេលវែងសម្រាប់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ។

**៦១-៤ សហប្រតិបត្តិការគម្រោង រៀបចំច្បាប់ ស្តីពីការសំគាល់ភូមិសាស្ត្រទំនិញ :**

-បានសហការ រៀបចំជាមួយ **លោកហ្សង់ ម៉ែរីប្រេង** អ្នកគ្រប់គ្រងគម្រោងនៃអង្គការហ្គ្រេត ( GRET ) ស្តីពីការផ្សព្វ ផ្សាយផលិតផលម្រេចកំពត នៅសហគមអឺរ៉ុប ក្នុងតំបន់ Aquitaine ប្រទេសបារាំង ។

-បានទទួលការបណ្តុះ បណ្តាលពីជំនាញការបារាំង គឺ លោក Charles Perraud និង Jean-Claude Pons ដើម្បីធ្វើ ការតាមដាន និងត្រួតពិនិត្យលើការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ និងសមាគមលើក កម្ពស់ម្រេចកំពត និងបានទទួលការបណ្តុះបណ្តាលពី **លោកស្រី ហៃឡែន ពីណូ** ជំនាញការបារាំង មកពីមជ្ឈមណ្ឌលនៃ វិទ្យាស្ថានជាតិនៃការហៅតាមប្រភពដើមផលិតផល នៅតំបន់ប៉ូ ( INAO center of PAU) ក្នុងការពិនិត្យបែបបទចុះបញ្ជី ផលិតផលសម្គាល់ភូមិសាស្ត្រ និងការការពារផលិតផល សម្គាល់ភូមិសាស្ត្រ ។

-បានធ្វើសំណើផ្លូវការនូវការបង្កើតកម្មវិធីថ្នាក់តំបន់ Regional Program on Geographical Indications Project សម្រាប់ ០៤ ប្រទេស ដោយបានស្នើសុំឱ្យបង្កើតការិយាល័យនេះនៅក្នុងប្រទេសកម្ពុជា ទៅទីភ្នាក់ងារបារាំង ដើម្បីការអភិវឌ្ឍន៏ (AFD) ដើម្បីពិចារណា និងសម្រេចលើបេក្ខភាពរបស់ប្រទេសកម្ពុជា ។

**៦១-៥-ការងារ បោះពុម្ពផ្សាយព្រឹត្តិប័ត្រផ្លូវការ**

ជាផ្នែកមួយតម្រូវដោយច្បាប់ ដើម្បីអោយការចុះបញ្ជីម៉ាក មានតម្លាភាព ទុកលទ្ធភាពអោយភាគីទី៣ មានសិទ្ធិប្តឹង ជំទាស់ទៅនឹងការចុះបញ្ជីម៉ាក នាយកដ្ឋានបាន បោះពុម្ពព្រឹត្តិប័ត្រផ្លូវការ (Official Gazette) បាន សរុប ចំនួន ១២ លេខ គឺ ពីលេខ ១០៧ ដល់ ១១៨ ដើម្បីផ្សព្វផ្សាយជាសាធារណៈ ។

**៦១-៦- គម្រោងកម្មសិទ្ធិបញ្ញា ៣៩ សកម្មភាព** (Pillar 1)

ក្នុងចំណោមគំរោងអនុវត្តកម្មសិទ្ធិបញ្ញាទាំង ៣៩ សកម្មភាព នាយកដ្ឋានបានរៀបចំជាគំរោងអាទិភាព និងបាន បំពេញបែបបទតាមគំរូរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំជំនួយពីធនាគារពិភពលោក និង អង្គការកម្មសិទ្ធិ បញ្ញាពិភពលោក ព្រមទាំងស្វែងរកដៃគូឧបត្ថម្ភផ្សេងទៀត ដើម្បីអនុវត្តគំរោងកម្មសិទ្ធិបញ្ញាទាំង ៣៩ សកម្មភាព អោយទទួល បាន លទ្ធផលល្អ ។

**៦១-៧- សហប្រតិបត្តិការគម្រោង** ECAP III

ចំពោះគម្រោង ECAP III នាយកដ្ឋានបានសហការអនុវត្ត ប្រកបដោយជោគជ័យ លើផ្នែកៈ

១-ការកសាងប្រព័ន្ធច្បាប់ និង បទប្បញ្ញត្តិផ្នែកកម្មសិទ្ធិបញ្ញា

២-ការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធគ្រប់គ្រងកម្មសិទ្ធិបញ្ញា

៣-ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា

៤-ការផ្សព្វផ្សាយចំណេះដឹងសាធារណៈ ។

និងបានចូលរួមតាក់តែង និង ផ្តល់យោបល់លើផែនការសកម្មភាព សម្រាប់អនុវត្តគំរោង ECAP III នៅឆ្នាំ ២០១០ជាបន្ត។

**៦១-៨- គម្រោងបង្កើនសម្ថភាពកម្មសិទ្ធិបញ្ញា និង ការអភិវឌ្ឍន៍ចេរភាព**

នាយកដ្ឋានបានសហការរៀបចំអនុវត្តគម្រោងបង្កើនសម្ថភាពកម្មសិទ្ធិបញ្ញា និង ការអភិវឌ្ឍន៍ចេរភាពនៅកម្ពុជា ដែលអនុវត្តដោយសន្និសិទសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និង ការអនុវត្ត (UNCTAD) និង មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ ពាណិជ្ជកម្ម និង ការអនុវត្តចេរភាព (ICTSD)។

គម្រោងនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង:

-បង្កើនការយល់ដឹងពីការវិវត្ត នៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា។

-ពង្រឹងសម្ថភាពមន្ត្រីរបស់កម្ពុជា លើការវិភាគ និង ចរចា ដើម្បីជំរុញអោយពួកគេអាចចូលរួមក្នុងការចរចារ ដែលពាក់ព័ន្ធទៅនឹងវិស័យកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងឆ្ពោះទៅរកការអភិវឌ្ឍន៍ ដែលមានចេរភាព។

**៦១-៩- សហប្រតិបត្តិការកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និង វិនិយោគ** (TIFA) **និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**

-បានចូលរួមប្រជុំអំពីទំនាក់ទំនងកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី រវាងកម្ពុជា-ជប៉ុន

-ផ្តល់យោបល់លើកិច្ចព្រមព្រៀងសេរីអាស៊ាន ASEAN-ANZ FTA និងរៀបចំសិទ្ធិប្រទានសម្រាប់ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

-ផ្តល់យោបល់លើលើកិច្ចព្រមព្រៀង ASEAN-EU Non paper

**៦១-១០ -ក្រុមការងារអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា** AWGIPC

នាយកដ្ឋានបានរៀបចំកិច្ចប្រជុំ AWGIPC លើកទី ៣២ ដែលបានប្រព្រឹត្តិទៅ ចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ និងបានផ្តល់យោបល់ទៅលើ

៦១-៧-១- កិច្ចសហប្រតិបត្តិការពិនិត្យខ្លឹមសារប្រកាសនីយបត្រតក្កកម្មអាស៊ាន (ASPEC) :

ASPEC ត្រូវបានផ្តួច ផ្តើមបង្កើតឡើង ដើម្បីផ្តល់លក្ខណៈងាយស្រួលដល់តក្កករ ដើម្បីទទួលបានការចុះបញ្ជីតក្កកម្មកាន់តែងាយស្រួលជាងមុន។ ASPEC កាត់បន្ថយពេលវេលានៃដំណើរការដាក់ពាក្យ និង ចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម និង កែលំអរគុណភាពស្រាវជ្រាវ និង របាយការណ៍ពិនិត្យខ្លឹមសារក្នុងចំណោមការិយាល័យកម្មសិទ្ធិបញ្ញាអាស៊ាន ដោយអនុញ្ញាត អោយការិយាល័យកម្មសិទ្ធិបញ្ញាអាស៊ាន អាចប្រើប្រាស់របាយការណ៍ពិនិត្យខ្លឹមសារដែលបានធ្វើឡើងមុននៅការិយាល័យកម្មសិទ្ធិ បញ្ញាអាស៊ានដទៃទៀត សម្រាប់យោងមករបាយការណ៍ពិនិត្យខ្លឹមសាររបស់ខ្លួនបាន។

៦១-៧-២- កម្មសិទ្ធិបញ្ញាផ្ទាល់ IP DIRECT :

ការផ្តួចផ្តើម IP DIRECT ដែលជាបញ្ជីព័ត៌មានតាមអាំងទែណែត ដែលផ្តល់ព័ត៌មាន នៃប្រភព និង សេវាដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា នៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលជាប្រភពបញ្ជរតែមួយ ដែលមានសារៈសំខាន់ និង ផលប្រយោជន៍ សម្រាប់ការធ្វើអាជីវកម្ម និងភាគី មានផលប្រយោជន៍ដទៃទៀត។ ដើមតំបូង IP DIRECT ផ្តល់ព័ត៌មាន ដែលពាក់ព័ន្ធ ច្បាប់កម្មសិទ្ធិបញ្ញា អង្គភាពអនុវត្តច្បាប់ និង ស្ថាប័នដោះស្រាយជម្លោះ ប្រភព នៃការផ្តល់

ប្រាក់ឧបត្ថមធន ប្រាក់កម្ចី និងការលើកទឹកចិត្តរបស់រដ្ឋាភិបាល សម្រាប់ការវិនិយោគ ក្នុងវិស័យស្រាវជ្រាវ និង ការអភិវឌ្ឍន៍ ការផ្ទេរ ការផ្តល់អជ្ញាបណ្ណ បច្ចេកវិជ្ជា អង្គភាពគ្រប់គ្រង សិទ្ធិរួម និងការអប់រំចំណេះដឹងកម្មសិទ្ធិបញ្ញា សាធារណៈ នៅអាស៊ាន។ ព័ត៌មាននៅក្នុងបញ្ជីត្រូវបាន បង្កើតឡើង ជាមួយនឹងតម្លៃកម្មសិទ្ធិបញ្ញា ដែលមានឈ្មោះថា ការច្នៃប្រឌិត ការបង្កើតថ្មី ការការពារ និង ការធ្វើអាជីវកម្ម និង ការអនុវត្តកម្មសិទ្ធិបញ្ញា។

១១-៧-៣- ការកម្រិត និង ការលើកលែងសិទ្ធិ អ្នកនិពន្ធ និង សិទ្ធប្រហាក់ប្រហែល :

កិច្ចប្រជុំរបស់ក្រុមការងារអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា ស្ថិតក្នុងការពិភាក្សាលើដំណើរការ កំណត់ការកម្រិត និង ការលើកលែងសិទ្ធិអ្នកនិពន្ធ និង សិទ្ធប្រហាក់ប្រហែល នៅក្នុងប្រព័ន្ធច្បាប់របស់ប្រជាជាតិដែលជាសមាជិក អាស៊ាន ដែលជាផ្នែកមួយនៃការបន្តសកម្មភាពកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា។ បញ្ហាសិទ្ធិអ្នកនិពន្ធគឺជាការដាក់ទម្ងន់ទៅលើ សមាជិកអាស៊ាន ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីរក្សាសមតុល្យរវាងផលប្រយោជន៍ របសម្ចាស់សិទ្ធិ និងផលប្រយោជន៍ សាធារណៈ ដោយសារមូហេតុនៃការកើនឡើងតម្រូវការពីសង្គម និង អ្នកពាក់ព័ន្ធក្នុងការចូលទៅកាន់ព័ត៌មាន ការស្រាវជ្រាវ ការសិក្សា និង ចំណេះដឹង កាន់តែទូលំទូលាយថែមទៀត ក្នុងគោលបំណងបង្កើតអោយមានផលិតផលវប្បធម៌សម្បូរបែប ។

## ១១-១១- កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Microsoft

បន្ទាប់ពីទទួលភារកិច្ច ដែលប្រគល់អោយពីគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានជួបប្រជុំគ្នា ចំនួន ០៣ លើក ដើម្បីពិភាក្សាលំអិតពីគុណសម្បត្តិ និងគុណវិបត្តិលើ អានុសារណៈយោគយល់គ្នា (Memorandum of Understanding) រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន Microsoft ស្តីពីការធ្វើកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើការងារបណ្តុះបណ្តាល អប់រំ តាមសាកលវិទ្យាល័យ និងមហាវិទ្យាល័យ ដោយដូរ ជាថ្នូរមកវិញនូវការប្រើប្រាស់កម្មវិធីកុំព្យូទ័រសុទ្ធ នៅតាមអង្គភាពរដ្ឋ មហាវិទ្យាល័យ និងវិទ្យាល័យរបស់កម្ពុជា។

## ១១-១២-អនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា

អនុគណៈកម្មាធិការនេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងអជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញាអោយរលូន និងមានប្រសិទ្ធិភាព។

នៅក្នុងកិច្ចប្រជុំរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ បានសម្រេចជ្រើសតាំងក្រសួងពាណិជ្ជកម្ម តាមរយៈការបោះឆ្នោត ធ្វើជាប្រធានអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ហើយអនុប្រធាននៃអនុគណៈកម្មាធិការនេះមានចំនួន៥គឺ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងទីស្តីការគណៈរដ្ឋមន្ត្រី ។ ចំណែកឯអនុប្រធានអចិន្ត្រៃយ៍ អង្គប្រជុំពុំទាន់បានសម្រេច អំពី សមាសភាពអនុប្រធានអចិន្ត្រៃយ៍នៅឡើយទេ។

សមាជិកនៃអនុគណៈកម្មាធិការ រួមមាន : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួង បរិស្ថាន ក្រសួងអប់រំ យុវជននិងកីឡា និង ក្រសួងទេសចរណ៍។

**៦១-១៣-អនុគណៈកម្មាធិការអប់រំ និងផ្សព្វផ្សាយ**

អនុគណៈកម្មាធិការនេះ មានភារកិច្ចបណ្តុះបណ្តាល និង ផ្សព្វផ្សាយកម្មសិទ្ធិបញ្ញា ទៅកាន់សាធារណៈ និង មានតួនាទីរៀបចំកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញា នៅតាមសាកលវិទ្យាល័យ មហាវិទ្យាល័យ វិទ្យាល័យ និងបកប្រែទៅជាភាសាខ្មែររាល់ឯកសារកម្មសិទ្ធិបញ្ញា សម្រាប់ការបង្រៀន ដើម្បីជាជំនួយដល់គ្រូបង្រៀន សិស្ស និងមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា។

អង្គប្រជុំបានសម្រេចជ្រើសរើស ក្រសួងពាណិជ្ជកម្មធ្វើជាប្រធាន ក្រសួង ក្រសួងអប់រំ ធ្វើជាអនុប្រធានអចិន្ត្រៃយ៍ ចំណែកឯអនុប្រធានធម្មតាមានចំនួន៤ទៀតគឺ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន និង ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល។ សមាជិកនៃអនុគណៈកម្មាធិការ រួមមានៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងមហាផ្ទៃ និង ទីស្តីការគណៈរដ្ឋមន្ត្រី។

**៦១-១៤-សេចក្តីពន្យល់នៃវិធាន សំរាប់អនុវត្ត មាត្រា ១១ និង មាត្រា ១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្របខណ្ឌអង្គការសុខភាពពិភពលោក**

សេចក្តីពន្យល់នៃវិធានសំរាប់ អនុវត្ត មាត្រា ១១ និង ១៣ នៃ អនុសញ្ញាស្តីពី ការត្រួតពិនិត្យថ្នាំជក់ ក្របខណ្ឌ អង្គការសុខភាពពិភពលោក បានហាមឃាត់ ចំពោះការប្រើប្រាស់ រូបភាព ពណ៌ ឬ ព័ត៌មាន នៅលើសំបកវេចខ្ចប់នៃផលិតផលថ្នាំជក់ ដែលមានភាពទាក់ទាញ ធ្វើអោយអតិថិជនភ័ន្តច្រឡំថា កាត់បន្ថយគ្រោះថ្នាក់ដល់សុខភាព និង ហាមឃាត់មិន អោយមានការផ្សាយពាណិជ្ជកម្ម ចំពោះទ្រង់ទ្រាយ សំបកវេចខ្ចប់ នៃផលិតផលថ្នាំជក់ ដែលរចនាឡើងធ្វើអោយមាន ភាពទាក់ទាញអារម្មណ៍ពីអតិថិជន។

ក្រសួងពាណិជ្ជកម្មបានធ្វើលិខិតផ្ញើជូនក្រសួងសុខាភិបាល ដើម្បីសម្តែងការព្រួយបារម្ភអំពីសេចក្តីពន្យល់ នៃវិធាន សំរាប់អនុវត្តមាត្រា ១១ និង ១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្នុងក្របខណ្ឌអង្គការសុខភាពពិភពលោក ដែលផ្ទុយនឹង ច្បាប់ម៉ាកពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នៃព្រះរាជាណាចក្រកម្ពុជា និង កិច្ចព្រមព្រៀងពាណិជ្ជកម្ម ទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញា (TRIPs) និង អនុសញ្ញាទីក្រុងប៉ារីស (Paris Convention) ។

**៦១-១៥-ការស្នើសុំបណ្តុះបណ្តាលធនធានមនុស្ស**

បន្ទាប់ពីកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា ក្រសួងដែលជាសមាជិករបស់គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា បានស្នើសុំបណ្តុះបណ្តាលច្បាប់កម្មសិទ្ធិបញ្ញា ៖

-ក្រសួងយុត្តិធម៌បណ្តុះបណ្តាល ចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង និងក្រឡាបញ្ជី ដែលកំពុងបំរើការនៅតាមតុលាការ រាជធានី-ខេត្ត ចំនួន ៩០៩ នាក់។

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បណ្តុះបណ្តាលមន្ត្រីចំនួន ០៥ នាក់។

## គ-កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ :

### គ១- ធនធានមនុស្ស :

ចំនួនមន្ត្រីរាជការក្នុងឆ្នាំ ២០០៩ ចំនួនមន្ត្រីរាជការសរុប ៦៤ រូប ក្នុងនោះ មន្ត្រីថ្នាក់នាយកដ្ឋាន ចំនួន ០៥ រូប និង ថ្នាក់ការិយាល័យ ចំនួន ២៤ រូប ។

### គ២-ការងារថវិកា :

ដោយគិតចាប់ពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៨ រហូតដល់ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ នាយកដ្ឋានបានបង់ប្រាក់ជូននាយកដ្ឋានរដ្ឋបាលបានចំនួន **891,100,000.00៛** (ប្រាំបីរយកៅសិបមួយលាន មួយរយពាន់រៀល) ដែលក្នុងនោះរួមមាន :

| | | |
|---|---|---|
| - កំរៃនៃការដាក់ពាក្យសុំចុះបញ្ជីម៉ាក | : | 61,540,000.00៛ |
| - កំរៃនៃការចុះបញ្ជីម៉ាក | : | 560,880,000.00៛ |
| - កំរៃនៃការបញ្ជាក់ ការប្រើប្រាស់ម៉ាក | : | 78,160,000.00៛ |
| - កំរៃនៃការផ្ទេរកម្មសិទ្ធិម៉ាក | : | 13,080,000.00៛ |
| - កំរៃនៃការប្តូរឈ្មោះម្ចាស់ម៉ាក | : | 23,960,000.00៛ |
| - កំរៃនៃការកែតំរូវនានា | : | 1,120,000.00៛ |
| - កំរៃនៃការក្នុងការប្តូរអស័យដ្ឋាន | : | 12,360,000.00៛ |
| - កំរៃក្នុងការលុបម៉ាកចេញពីបញ្ជី | : | 2,200,000.00៛ |
| - កំរៃក្នុងការចុះបញ្ជីសាឡើងវិញ | : | 137,800,000.00៛ |
| | **សរុបៈ** | **891,100,000.00៛** |

**សន្និដ្ឋាន :**

ប្រៀបធៀបនឹងការបង់ចំណូលជូនរដ្ឋឆ្នាំ ២០០៨ បានចំនួន **728,920,000.00៛** យើងឃើញថា មានការកើនឡើង **162,180,000.00៛** ស្មើនឹង **22,2**ភាគរយ ដោយអនុវត្តន៏តាមប្រកាសរួម រវាងក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីកំរៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និង កំរៃរដ្ឋបាលពាក់ព័ន្ធ។

## ឃ- កិច្ចការជំនាញពាណិជ្ជសញ្ញា :

### ឃ១-ការចុះបញ្ជីពាណិជ្ជសញ្ញា :

គិតរហូតដល់ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ នាយកដ្ឋានបាន :

**១-ទទួលពាក្យស្នើសុំថ្មី :** ៣០៧៧ ម៉ាក

-ក្នុងស្រុកៈ ៨០៦ ម៉ាក ក្រៅស្រុកៈ ២២៧១ ម៉ាក

**២- ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មី :** ៣១១៦ ម៉ាក

ក្នុងស្រុក ៦៩៨ ម៉ាក ក្រៅស្រុក ២៤១៨ ម៉ាក

### ៣- កិច្ចការក្រោយចុះបញ្ជី

- ការប្តូរឈ្មោះអាស័យដ្ឋាន : ៣០៩ ម៉ាក
- ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ម៉ាក : ១៩៥៤ ម៉ាក
- ការកែតំរូវ : ២៨ ម៉ាក
- ការផ្ទេរសិទ្ធិ ម្ចាស់ម៉ាក : ៣២៧ ម៉ាក
- ការប្តូរឈ្មោះ រឺបញ្ចូលគ្នានៃម្ចាស់ម៉ាក : ៥៩៩ ម៉ាក
- ការចុះបញ្ជីម៉ាកសាឡើងវិញ : ៦៨៩ ម៉ាក
- ការលុបម៉ាក : ១១ ម៉ាក

**៤-ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ :** ០២ ម៉ាក

**សន្និដ្ឋាន :**

**១-**ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០០៩ សរុបចំនួន ៣០៧៧ ម៉ាក ក្នុងនោះពាក្យស្នើសុំចុះបញ្ជីការពារម៉ាកក្នុងស្រុកមានចំនួន ៨០៦ ម៉ាក និង ក្រៅស្រុកមានចំនួន ២២៧១ ម៉ាក ហើយបើប្រៀបធៀបទៅនឹងការទទួលពាក្យស្នើសុំចុះបញ្ជី ការពារម៉ាកក្នុងឆ្នាំ ២០០៨ ឃើញថាមានការថយចុះចំនួន ២២ ម៉ាក ស្មើនឹង -0,៧% ។ ការថយចុះការទទួលពាក្យស្នើសុំចុះបញ្ជីការពារម៉ាកនេះ បណ្តាលមកពីវិបត្តិហិរញ្ញវត្ថុពិភពលោក បានជះឥទ្ធិពលមក លើក្រុមហ៊ុនផលិតករ និងអាជីវករ ។

ទន្ទឹមនឹងការថយចុះនៃការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០០៩ នេះ យើងសង្កេតឃើញថា ការទទួលពាក្យស្នើសុំចុះបញ្ជីការពារម៉ាកក្នុងស្រុកមានការកើនឡើងចំនួន ២២៨ ម៉ាក ។ ការកើនឡើងការទទួលពាក្យស្នើសុំចុះបញ្ជីការពារម៉ាកក្នុងស្រុកនេះ បណ្តាលមកពីក្រុមហ៊ុន ផលិតករ និងអាជីវករ។ កត្តានេះបានឆ្លុះបញ្ចាំងអោយឃើញថា សេដ្ឋកិច្ចកម្ពុជាមានភាពរីកចំរើន ពិសេសក្នុងវិស័យផលិតកម្ម និង សេវាកម្ម ព្រមទាំងការយល់ដឹងពីអត្ថប្រយោជន៍ក្នុងការចុះបញ្ជីម៉ាករបស់អាជីវករ ផលិតករ តាមរយៈការផ្សព្វផ្សាយច្បាប់កម្មសិទ្ធិបញ្ញាជាច្រើនឆ្នាំកន្លងមក មានការយល់ដឹងកាន់តែច្រើនឡើង។

**២-**ការចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០០៩ សរុបមានចំនួន ៣១១៦ ម៉ាក ក្នុងនោះម៉ាកក្នុងស្រុកមានចំនួន ៦៩៨ ម៉ាក ម៉ាកក្រៅស្រុកមានចំនួន ២៤១៨ ម៉ាក ។ បើប្រៀបធៀបការចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០០៨ កន្លងមកឃើញថា មានកើនឡើងចំនួន ៨០៥ ម៉ាក ស្មើនឹង ៣៤,៨% ក្នុងនោះការចុះបញ្ជីម៉ាកក្នុងស្រុកមានការកើនឡើងចំនួន ២៦១ ម៉ាក និង ការចុះបញ្ជីម៉ាកក្រៅស្រុកមានការកើនឡើងចំនួន ៥៤៤ ម៉ាក ។

*កត្តាចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០០៩ មានការកើនឡើង ដោយសារ :*

ក- ការត្រួតពិនិត្យម៉ាកដោយប្រើប្រព័ន្ធ IPAS កាន់តែមានភាពស្ទាត់ជំនាញ

ខ- ឯកសារឆ្លើយឆ្លង ប្រគល់ និងទទួលបានឆាប់រហ័ស

គ- ឯកសារចេញគោលការណ៍ចុះបញ្ជីជូន មួយចំនួនសល់ពីឆ្នាំ២០០៧ - ២០០៨ កន្លងមក

## ឃ២-ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និង ការលុបម៉ាកចេញពីបញ្ជី

### ឃ២-១-ការទទួលពាក្យបណ្តឹង

ក្នុងឆ្នាំ ២០០៩ នេះ នាយកដ្ឋានបានទទួលពាក្យដោះស្រាយវិវាទសរុបចំនួន ២៧ករណី ក្នុងនោះរួមមានពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពាន (សូមមើលតារាង **ក**) មានចំនួន ១៣ ករណី ស្មើនឹង ៤៨% និងពាក្យបណ្តឹងស្នើសុំលុបម៉ាក (សូមមើលតារាង **ខ**) មានចំនួន ១៤ ករណី ស្មើនឹង ៥២% នៃការទទួល ពាក្យសរុប ។

**តារាង ក**

| ស្ថិតិនៃការរំលោភបំពានកម្មសិទ្ធិបញ្ញាក្នុងឆ្នាំ ២០០៩ | | | | |
|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | ការដោះស្រាយ | | នៅសល់ |
| | | ការបដិសេធន៍ និងដកពាក្យបណ្តឹង | ការសំរបសំរួល | |
| ២០០៨ | ៥ | | | |
| ២០០៩ | ១៣ | ៣ | ៩ | |
| **សរុប** | **១៨** | **៣** | **៩** | **៦** |

**តារាង ខ**

| ស្ថិតិនៃការលុបម៉ាកក្នុងឆ្នាំ ២០០៩ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | | ការដោះស្រាយ | | | | | | នៅសល់ | |
| | | | ការបដិសេធន៍ និង ដកពាក្យបណ្តឹង[1] | | ឡុប | | កែតំរូវ | | | |
| | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក |
| ២០០៨ | ៩ | ១១ | | | | | | | | |
| ២០០៩ | ១៤ | ២០[2] | ២ | ៤ | ១១ | ១២[3] | ៣ | ៤ | | |
| **សរុប** | **២៣** | **៣១** | **២** | **៤** | **១១** | **១២[3]** | **៣** | **៤** | **៧** | **១១** |

*១: ការបដិសេធន៍ពាក្យបណ្តឹងជាបឋម ការទាត់ចោលពាក្យបណ្តឹងដែលមានមូលដ្ឋានមិនអាចលុបម៉ាកបាន និងការសុំដកពាក្យបណ្តឹង ដោយសាមីខ្លួន ។*

*២: ១៩ម៉ាក និងឈ្មោះក្រុមហ៊ុន ១*

*៣: ១១ម៉ាក និងឈ្មោះក្រុមហ៊ុន ១*

***សំគាល់*** *រាល់ពត៌មានលំអិត ស្តីពីការទទួលពាក្យ ការដោះស្រាយការរំលោភបំពាន និងការលុបម៉ាកចេញពីបញ្ជី មានតំកល់នៅ កាិយាល័យវិវាទ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ។*

### ឃ២-២-ការដោះស្រាយការរំលោភបំពាន

ក្នុងឆ្នាំ ២០០៩ នេះ នាយកដ្ឋានបានពិនិត្យពាក្យបណ្តឹងចំនួន **១៨** ករណី (ក្នុងឆ្នាំ ២០០៩ ទទួលបាន **១៣** ករណី និងសល់ពីឆ្នាំមុន **៥** ករណី) និងបានដោះស្រាយការរំលោភបំពានបានចំនួន **១២** ករណី ក្នុងនោះរួមមាន ការធ្វើការសំរបសំរួល ដោយមានកំណត់ហេតុចំនួន **៧** ករណី ធ្វើលិខិតជូនដំណឹងជា សាធារណចំនួន **២** ករណី បដិសេធ **២** ករណី ព្រោះគ្មានមូលដ្ឋានផ្លូវច្បាប់ និង ដើមចោទបានបង្ហាញចុង ចំលើយមិនត្រឹមត្រូវ និងដកពាក្យបណ្តឹងដោយដើមបណ្តឹងវិញ **១** ករណី ដោយសារម្ចាស់ ម៉ាកបានប្តូរជំហរ ហើយនៅសល់ **៦** ករណីទៀត នាយកដ្ឋាន កំពុងបន្តពិនិត្យ និងដោះស្រាយ (សូមមើលតារាង **ឥ**)។

### ឃ២-៣-ការលុបម៉ាកចេញពីបញ្ជី

ក្នុងឆ្នាំ ២០០៩ នេះ នាយកដ្ឋានក៏បានពិនិត្យពាក្យបណ្តឹងលុបម៉ាកចំនួន **២៣** ករណី (ក្នុងឆ្នាំ ២០០៩ ទទួលបាន **១៤** ករណី និងនៅសល់ពីឆ្នាំមុន **៩** ករណី) និងបានដោះស្រាយចំនួន **១៦** ករណី ក្នុងនោះរួមមាន ការលុបម៉ាកចេញពីបញ្ជីចំនួន **១០** ករណី ស្មើនឹង ១១ម៉ាក និងលុបឈ្មោះក្រុមហ៊ុន ១ករណី ស្មើនឹងឈ្មោះក្រុមហ៊ុន ១ កែតំរូវម៉ាកសាជាថ្មីចំនួន **៣** ករណីស្មើនឹង **៤**ម៉ាក និងទាត់ចោល **១** ករណី ព្រោះគ្មានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ ដើម្បីលុបម៉ាកទាំងនោះបាន ហើយនៅសល់ **៧**ករណី ស្មើនឹង ១១ម៉ាកទៀត នាយកដ្ឋាន កំពុងបន្តពិនិត្យ និងដោះស្រាយ (សូមមើលតារាង **ឱ**)។

### ឃ២-៤-ការប្រៀបធៀប

បើធ្វើការប្រៀបធៀបការទទួលពាក្យបណ្តឹងរំលោភបំពានពាណិជ្ជសញ្ញាក្នុងឆ្នាំ ២០០៩ នេះ នឹង ឆ្នាំ ២០០៨ គឺមានការថយចុះ ចំនួន ១ ករណី ហើយការទទួលពាក្យបណ្តឹងលុបម៉ាកចេញពីបញ្ជី ក៏មានការថយចុះចំនួន១ ករណីផងដែរ។ ចំណែកលទ្ធផលនៃ ការដោះស្រាយការរំលោភបំពានក្នុងឆ្នាំ ២០០៩ មានចំនួន ៩ ករណី គឺថយចុះចំនួន ១ ករណី ប្រៀបនឹងឆ្នាំ ២០០៨ ឯការលុបម៉ាកចេញពីបញ្ជីមានចំនួន ១០ ករណី ស្មើនឹង ១១ម៉ាក គឺថយចុះចំនួន ៤ ម៉ាក នេះជាសូចនាករមួយបង្ហាញអោយឃើញថា សកម្មភាពពាណិជ្ជកម្មមានភាពរីកលូតលាស់កាន់តែប្រសើរឡើង ទន្ទឹមនឹងនេះ ការរំលោភបំពានកម្មសិទ្ធិបញ្ញា ក៏នៅតែមានផងដែរ ឬថាការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជ្រាបចូលក្នុងស្រទាប់មហាជន ជាសន្សឹមៗ ហើយម្ចាស់កម្មសិទ្ធិបញ្ញា បានចាប់អារម្មណ៍ដល់ការការពារផលប្រយោជន៍ដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ដោយផ្តួចផ្តើម ចាត់វិធានការចំពោះការរំលោភបំពាន ទាំងនោះ ទៅតាមស្ថាប័នអនុវត្តកម្មសិទ្ធិបញ្ញា ដែលមានស្រាប់។

### សន្និដ្ឋាន

សកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា នៅតែជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ហើយការអនុវត្តន៍កម្មសិទ្ធិបញ្ញា មិនអាចប្រព្រឹត្តទៅបានដោយរលូនទេ ប្រសិនបើម្ចាស់កម្មសិទ្ធិបញ្ញា នៅតែប្រងើយកន្តើយចំពោះការរំលោភបំពានទាំងនោះ គួរតែម្ចាស់កម្មសិទ្ធិបញ្ញាសហការជាមួយសមត្ថកិច្ច ដើម្បីទប់ស្កាត់ការរំលោភបំពានអោយកាន់តែមានប្រសិទ្ធិភាព ដើម្បីលើកស្ទួយ ការបង្កើតសម្បត្តិកម្មសិទ្ធិបញ្ញា និង ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

## II-ទិសដៅអនុវត្តការងារសំរាប់ ឆ្នាំ ២០១០

នាយកដ្ឋានមានទិសដៅអនុវត្តការងារ ដូចខាងក្រោម :

**ក-ការងារកសាងសិក្សាច្បាប់ និង បទបញ្ញត្តិកម្មសិទ្ធិបញ្ញា ផ្សេងៗ :**

**១-ការងារកសាងសិក្សាច្បាប់ និង បទបញ្ញត្តិកម្មសិទ្ធិបញ្ញា ផ្សេង១ :**

**ក១-** បន្តបញ្ចប់ការរៀបចំច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ (Law on Geographical Indications) និង ដាក់ជូនសុំការអនុម័តពីគណៈរដ្ឋមន្ត្រី និង សភាជាតិ ឆ្នាំ ២០០៩។

**ក២-**បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារ ការសម្ងាត់ពាណិជ្ជកម្ម និង ពត៌មានសំងាត់ (Law on the Protection of Trade Secrets and Undisclosed Information) និង ពិនិត្យឡើងវិញទៅលើ សេចក្តីព្រាងច្បាប់ជាភាសាខ្មែរអោយបានកាន់តែ ល្អិតល្អន់ និងកាន់តែស៊ីជំរៅ និងរាវរកផលប៉ះពាល់ ទាំងឡាយណា ទៅលើច្បាប់ដែលមានស្រាប់ របស់អន្តរក្រសួងនីមួយៗ និងឈាន ទៅបញ្ចប់សេចក្តីព្រាង ច្បាប់នេះជាស្ថាពរនា ឆ្នាំ២០០៩ នេះ។

**ក៣**-សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យ ស្តីពី " វិធានការណ៍តាមព្រំដែន " ដែលចែងលំអិត អំពីនិតិវិធីអនុវត្តការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតាមព្រំដែន ដោយអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើ ម៉ាកប្រកាសនីយប័ត្រតក្កកម្ម និង សិទ្ធិអ្នកនិពន្ធ ដាក់ពាក្យទៅអាជ្ញាធរគយ ឬ កាំកុងត្រូលជាមុន ដើម្បីផ្អាកការនាំចូលទំនិញ ដែលសង្ស័យ ឬ មានការរំលោភបំពានកម្មសិទ្ធិបញ្ញា។

**ក៤**- សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យ ស្តីពី " ការត្រួតពិនិត្យ ការផលិត ការនាំចូល ថាស (CDs) " ក្នុងគោល បំណងការពារកុំឱ្យកម្ពុជា ក្លាយជាប្រទេសផលិត CDs ក្លែងក្លាយក្នុងបរិមាណច្រើន ហើយនាំចេញទៅ ប្រទេសក្រៅ។

**ក៥**- ជំរុញ និង សហការណ៍ជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ ក្នុងការរៀបចំព្រាងអនុក្រិត្យ ស្តីពី "ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម "ក្នុងគោលបំណងប្រមូលលាភការដល់អ្នកសំដែង និងអ្នកផលិតហ្វូណូក្រាម ។

**ក៦**- បន្តជំរុញ និង សហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការពិនិត្យសេក្តីព្រាង ច្បាប់ស្តីពី " ស្ញើគ្នី រួមបញ្ចូលគ្នា" ឱ្យបានសមស្របតាមស្តង់ដាអន្តរជាតិ។

**ក៧**- បន្តរៀបចំប្រកាសក្រសួង ស្តីពី" ការណែនាំក្នុងការចុះបញ្ជីម៉ាក" ឱ្យបានក្នុងឆ្នាំ ២០០៩ ឬ ២០១០ ខាងមុខ។

**ក៨**- បន្តរៀបចំប្រកាសក្រសួង ស្តីពី " ភ្នាក់ងារតំណាងចុះបញ្ជី និង ការពារម៉ាកនៅកម្ពុជា " ឱ្យបាន ក្នុងឆ្នាំ ២០០៩ ដើម្បីបង្រៀនដល់ភ្នាក់ងារតំណាងទាំងនោះឱ្យបានក្នុងឆ្នាំ ២០១០ ខាងមុខ។

**ក៩-** បន្តសិក្សាស្រាវជ្រាវនីតិវិធីចុះបញ្ជី និង ការការពារម៉ាកល្បី និង រៀបចំប្រកាសក្រសួង អំពីការ អនុវត្តនីការចុះបញ្ជីម៉ាកល្បី ក្នុងដើមឆ្នាំ ២០០៩ ឬ ២០១០ ខាងមុខ។

**ក១០-** បន្តសិក្សាស្រាវជ្រាវ ក្នុងការរៀបចំអនុក្រឹត្យ ស្តីពី " ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា (Sub-Decree on Enforcement of IPRs)" ក្នុងគោលបំណងចាត់វិធានការណ៍ឱ្យមានប្រសិទ្ធិភាពជាងមុន ដោយកិច្ចសហការ រវាងអង្គភាពពាក់ព័ន្ធ ដូចជា តុលាការ ព្រះរាជអាជ្ញា ប៉ូលីសសេដ្ឋកិច្ច និង នាយកដ្ឋាន ទទួលបន្ទុកកម្មសិទ្ធិបញ្ញានានា។

**ក១១-** សហការពិនិត្យច្បាប់ ប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរ ឧស្សាហកម្ម ជាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីអាចទាញយកអត្ថប្រយោជន៍ពីឋានៈ ប្រទេសក្រីក្រ (LDCs) នៃកម្ពុជា ក្នុងការធ្វើវិសោធនកម្មច្បាប់ខាងលើ និង ឬ រៀបចំច្បាប់បន្ថែមថ្មីស្តីពី "ការផ្តល់អាជ្ញាប័ណ្ណបញ្ជាសំរាប់សុខភាពសាធារណៈ" ដែលជាអត្ថប្រយោជន៍ ក្នុងការផលិតឱសថទូទៅ "អនេរិចរុងស" នៅកម្ពុជា ក៏ដូចជាការនាំចេញ-នាំចូល នូវប្រភេទឱថសខាងលើ ។

**ក១២-** ការសហការពិនិត្យផលចំនេញ និងប៉ះពាល់ក្នុងការចូលពិធីសាទីក្រុងម៉ាឌ្រីត កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត និង សន្ធិសញ្ញាស្តីពីម៉ាក របស់ប្រទេសសឹង្ហបុរី ។

**ក១៣-** សហការរៀបចំកម្មវិធីសិក្សាសំរាប់ថ្នាក់មហាវិទ្យាល័យ និងមហាជន

**ក១៤-** ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យ និងនាយកដ្ឋាន ដើម្បីអាចធ្វើជាគ្រូបង្ហាត់ វិស័យកម្មសិទ្ធិ បញ្ញា ។

## ២-អភិក្រមគ្របដណ្តប់វិស័យកម្មសិទ្ធិបញ្ញា (Trade SWAP)

ដើម្បីពង្រឹងប្រព័ន្ធជាតិ អោយខ្លាំងបន្ថែមទៀតខាងកំណើតកម្មសិទ្ធិបញ្ញា ការការពារកម្មសិទ្ធិបញ្ញា រដ្ឋបាលកម្មសិទ្ធិបញ្ញា និងការអនុវត្តន៏កម្មសិទ្ធិបញ្ញាដើម្បីអោយស្របទៅនឹង ស្តង់ដាកម្មសិទ្ធិបញ្ញាអន្តរជាតិ និងដើម្បីគ្រាំទ្រទិសដៅអភិវឌ្ឍន៏ពាណិជ្ជកម្ម របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ការិយាល័យមានផែន ការអនុវត្តគំរោងអាទិភាព នៃគំរោងសកម្មភាពកម្មសិទ្ធិបញ្ញាទាំង ៣៩ នៅឆ្នាំ ២០០៩-២០១០ ។

- បង្កើនល្បឿនក្នុងការពិនិត្យដោះស្រាយពាក្យបណ្តឹង ស្នើសុំទប់ស្កាត់ការរំលោភបំពានម៉ាក ក៏ដូច ជាពាក្យបណ្តឹងលុបម៉ាក អោយបានឆាប់ជៀសវាងការកកស្ទះ ដែលជះឥទ្ធិពលមិនល្អដល់ការអនុវត្តន៏ ច្បាប់ កម្មសិទ្ធិបញ្ញា នៅកម្ពុជា ។

- រក្សានិរន្តរភាពរៀបចំកត់ត្រា គ្រប់គ្រង និងចាត់ការពាក្យបណ្តឹងអោយមានលំហូរទៅតាមនីតិវិធី ដែលកំណត់ដោយច្បាប់ និង មានលក្ខណៈជាប្រព័ន្ធ ។

- បន្តតាមដានដាក់លក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាក ដែលមានវិវាទ ក្នុងប្រព័ន្ធ IPAS ដើម្បីធានាដល់ ប្រសិទ្ធភាពការងាររបស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា ។

- ក្រើនរំលឹកដល់មន្ត្រីអោយកែតំរូវផ្នត់គំនិតអសកម្ម ដោយប្រកាន់យកវប្បធម៏សហការការងារ ជាសារីន្ត ក្នុងការសិក្សាស្រាវជ្រាវបង្កើនការយល់ដឹងផ្នែកដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាបរទេស មានដូចជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ វិធាននៃមជ្ឈត្តកម្ម និង សន្ធានកម្ម ដើម្បីពង្រីកសមត្ថភាពក្នុងការពិនិត្យ និង ដោះស្រាយពាក្យបណ្តឹងអោយកាន់តែមានប្រសិទ្ធភាព ។

- ប្រកាន់ខ្ជាប់វប្បធម៏ណែនាំ បញ្ចុះបញ្ចូលអោយអ្នករំលោភបំពានផ្នែកកម្មសិទ្ធិបញ្ញា ប្រែក្លាយខ្លួនអោយទៅជាម្ចាស់ កម្មសិទ្ធិបញ្ញា ដែលជាកញ្ចប់ទុនជាតិមួយ ក្នុងការអភវឌ្ឍនីសេដ្ឋកិច្ចជាតិ ។

-រៀបចំឯកសារទាក់ទងនឹងការងារវិវាទ ដើម្បីផ្សព្វផ្សាយ និង បណ្តុះបណ្តាលដល់សិស្ស និង សាធារណជន ។

## ខ-ការងារបច្ចេកទេសដែលពាក់ពន្ធ នឹងវិស័យកម្មសិទ្ធិបញ្ញា :

នាយកដ្ឋានមានគោលការណ៍ធ្វើឱ្យទំនើបឡើង នូវប្រព័ន្ធគ្រប់គ្រង និងចុះបញ្ជីពាណិជ្ជសញ្ញាដោយៈ

-បន្តបញ្ចូលទិន្នន័យម៉ាក ដែលបានចុះបញ្ជីហើយទៅក្នុង Computer Database តាមប្រព័ន្ធ IPAS

-ពង្រឹងដំណើរការត្រួតពិនិត្យម៉ាកដោយស្វ័យប្រវត្តិ តាមរយៈ Computer ចំពោះម៉ាកជារូបភាព។

-បន្តរៀបចំកែលំអរប្រព័ន្ធចុះបញ្ជីម៉ាក តាមរយៈស្វ័យប្រវត្តិកម្ម (Computerization of Trademark Registration ) អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ និង សុក្រឹត្យ ។

-ជូនដំណឹងដល់អតិថិជន អោយមកចុះបញ្ជីម៉ាករបស់ខ្លួនសាជាថ្មី បន្ទាប់ពីបានចុះបញ្ជីរយពេល ១០ឆ្នាំ រួច។

-រៀបចំឱ្យមានមជ្ឈមណ្ឌលពតិមានកម្មសិទ្ធិបញ្ញាមួយ សំរាប់បំរើដល់អតិថិជនដែលមានបំណង ចង់ស្វែងយល់ពីកម្មសិទ្ធិបញ្ញា និយាយរួម និង និយាយដោយឡែក ពីម៉ាកដែលបានចុះបញ្ជីរួចហើយ ឬ ឯកសារនានា ដែល ទាក់ទង និង ការចុះបញ្ជីម៉ាក និង វិវាទនានានៅកម្ពុជា ។

-រៀបចំយន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់មហាជន និង អាជីវករ អំពីច្បាប់ដែល ទាក់ទង នឹងកម្មសិទ្ធិបញ្ញា ជាពិសេសច្បាប់ស្តីពីម៉ាកដើម្បីបង្កើនការយល់ដឹងរបស់ពួកគេ ។

-រៀបចំបោះពុម្ពផ្សាយ នូវព្រឹត្តិប័ត្រផ្លូវការអោយបាន ចំនួន ១២លេខ ក្នុងមួយឆ្នាំ ព្រមទាំងបញ្ចូល ឯកសារទៅក្នុង CD ដើម្បីចែកជូនអតិថិជន ក្នុង និង ក្រៅប្រទេស ដែលបានចុះបញ្ជីការពារម៉ាក របស់ខ្លួននៅកម្ពុជា និង ខិតខំធ្វើព្រឹត្តិប័ត្រផ្លូវការជា CDs ។

-ពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ដោយបង្កើនកិច្ចសហការអោយបានកាន់តែជិតស្និទ្ធិថែមទៀត ជាមួយស្ថាប័នមាន សមត្ថកិច្ច ដើម្បីកាត់បន្ថយការរំលោភកម្មសិទ្ធិបញ្ញាអោយបានជាអតិបរមា ។

-បង្កើនសមត្ថភាពយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា កុំព្យូទ័រ និង ភាសាអង់គ្លេស ដល់មន្ត្រីជំនាញរបស់ នាយកដ្ឋាន និង អង្គភាព ពាក់ព័ន្ធតាមរយៈការបញ្ជូនទៅបណ្តុះបណ្តាលវគ្គហ្វឹកហ្វឺនក្នុង និង ក្រៅប្រទេស។

-បន្តរៀបចំគំរូពាក្យស្នើសុំ និង គំរូលិខិតស្នាមផ្សេងៗទៀត ជាភាសាខ្មែរ និង អង់គ្លេស ដើម្បីងាយស្រួលដល់ការអនុវត្ត ការងារចុះបញ្ជីម៉ាក ឱ្យបានកាន់តែប្រសើរឡើងថែមទៀត។

-បន្តសហការជាមួយគណកម្មការជាតិគ្រប់គ្រងកម្មសិទ្ធបញ្ញា ដើម្បីបញ្ចប់ឱ្យបានឆាប់នូវសេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីតាមវេលាសមស្របណាមួយ ។

ភ្នំពេញ.ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩

**ប្រធាននាយកដ្ឋាន**